

ASIA LOW CARBON BUILDINGS TRANSITION PROJECT
Life Cycle Assessment for Transitioning to a Low-Carbon Economy

# ២.៧

# កម្ពុជា៖ បទប្បញ្ញត្តិ និងគោលនយោបាយថាមពលក្នុងផ្នែកសំណង់អគារ

ខែកុម្ភៈ ឆ្នាំ២០២៦

Supported by:
Federal Ministry for the Environment, Climate Action, Nature Conservation and Nuclear Safety
based on a decision of the German Bundestag
IKI INTERNATIONAL CLIMATE INITIATIVE

# អ្វីដែលអ្នកនឹងរៀន?

01 — សាវតានៃការអភិវឌ្ឍន៍ គោលនយោបាយ & ក្រម

02 — គោលនយោបាយ ប្រសិទ្ធភាព ថាមពលជាតិ (NEEP)

03 — រចនាសម្ព័ន្ធស្ថាប័ន សម្រាប់អនុវត្ត គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ (NEEP)

04 — ស្ថានភាពអនុវត្តន៍ បញ្ហាប្រឈម និងឧបសគ្គ

05 — ដំណើរឆ្ពោះទៅមុខ



# ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ GHGs

## ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅប្រទេសកម្ពុជាតាមវិស័យ

យោងតាមផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រិតភាពកាបូនសម្រាប់ប្រទេសកម្ពុជា វិស័យព្រៃឈើ និងការប្រើប្រាស់ដី (FOLU) មានចំណែក 51 MtCO2e (លានតោននៃសមមូលកាបូន) ដែលជាចំណែកដ៏ធំបំផុតនៃការបំភាយឧស្ម័ននៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ 2016។ ការកាប់បំផ្លាញព្រៃឈើជាមូលហេតុចម្បងនៃការបំភាយឧស្ម័ន ។

ឆ្នាំ 2020: ការបំភាយឧស្ម័នដ៏ធំបំផុតមកពី FOLU។

BAU 2050 : វិស័យដែលបញ្ចេញឧស្ម័នធំជាងគេគឺវិស័យថាមពល។




ការព្យាករណ៍លើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាម BAU តាមវិស័យ

*ប្រភព៖ March 13, 2024, One Planet Two Realities; Realizing Energy Transition in Global South, S&P Global*

# ការប្រែប្រួលអាកាសធាតុ

## ហានិភ័យ និងភាពងាយរងគ្រោះរបស់កម្ពុជា

*គោលដៅសេដ្ឋកិច្ចៈ*
2030 – ប្រទេសមានចំណូលមធ្យមកំរិតខ្ពស់
2050 – ប្រទេសមានចំណូលខ្ពស់

*ហានិភ័យការប្រែប្រួលអាកាសធាតុៈ*
គ្រោះទឹកជំនន់ និងកម្តៅតំបន់ទីក្រុង

ប្រទេសកម្ពុជា ក៏ទទួលនូវបទពិសោធន៍សីតុណ្ហភាពខ្ពស់បំផុតក្នុងពិភពលោក ដែលប៉ាន់ស្មានជាមធ្យម មានប្រហែលជា ***64 ថ្ងៃ ក្នុងមួយឆ្នាំ នៅពេលដែលមានសីតុណ្ហភាពអតិបរមាលើសពី 35°C***, ដែលជាប្រទេសមានចំណាត់ថ្នាក់ខ្ពស់លំដាប់ទី ***23 ដែលមានការទទួលរងនូវការប៉ះពាល់កម្តៅអាក្រក់ខ្លាំង។***

**ភ្នំពេញទទួលរងនូវឥទ្ធិពលកម្តៅតំបន់ទីក្រុងខ្ពស់ជាងគេ ដោយមានសីតុណ្ហភាព 1.16°C នៅកណ្តាលតំបន់ទីក្រុង ខ្ពស់ជាងកម្តៅនៅតំបន់ជាយក្រុង**

សន្ទស្សន៍កម្តៅតំបន់ទីក្រុង (ពណ៌ក្រហម=ក្តៅជាង, ពណ៌ខៀវ=ត្រជាក់ជាង)




*Source: World Bank analysis and 4EarthIntelligence (2023). These figures display the spatially disaggregated heat index for Phnom Penh over time. The black line denotes the city boundary. The urban heat island effect refers to the difference in temperature between the central urban area and the temperature 5 km outside the center.*

*ប្រភពៈ កម្ពុជា, របាយការណ៍អភិវឌ្ឍ និងអាកាសធាតុប្រទេស, ធនាគារពិភពលោក, កញ្ញា 2023*

# ការបំភាយឧស្ម័ន & ផលិតផលក្នុងស្រុក GDP

## ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅប្រទេសកម្ពុជាតាមវិស័យសំណង់ និងភាពពាក់ព័ន្ធទៅនឹង GDP

**សេដ្ឋកិច្ចកសិកម្ម**

***អន្តរកម្ម*** | ***ពី 1990 - បច្ចុប្បន្ន***

**សេដ្ឋកិច្ចឧស្សាហកម្មតម្រង់ទិសការនាំចេញ៖ រោងចក្រ ស្បែកជើង វាយនភ័ណ្ឌ**

**ប្រទេសកម្ពុជាមានអត្រាកំណើនការបំភាយឧស្ម័នលឿនជាងគេបំផុត** ដែលជាអន្តរកាលនៃហានិភ័យ

**ជាសេដ្ឋកិច្ចបញ្ចេញកាបូនច្រើន**ខ្លាំងជាងគេបន្ទាប់ពីប្រទេសមីយ៉ាន់ម៉ា

**ប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់**ដែលមានកំណើនលឿនខ្ពស់ជាងគេ គឺ **អគ្គិសនី និងការផលិតកម្ដៅ** ការផ្ដល់ភាពត្រជាក់ និងការប្រើប្រាស់ឧស្សាហកម្ម។

**សរសរស្ដម្ភស្នូល**នៃឧស្សាហកម្មសំណង់ និង **កត្តារួមចំណែកសំខាន់ៗ**សម្រាប់ **GDP** នឹងជះឥទ្ធិពលដល់ការបញ្ចេញឧស្ម័នតាមវិស័យនានា។

**FIGURE 1.** Growth and breakdown of the Cambodian GDP per sector




Source: MEF (2022)

*ប្រភព៖ Source: Ministry of Economy & Finance, 2022*

# ច្បាប់ & បទប្បញ្ញត្តិ

## ការប្រែប្រួលអាកាសធាតុ និងប្រសិទ្ធភាពថាមពលអគារនៅប្រទេសកម្ពុជា

1. **ច្បាប់អគ្គសនី 2001 វិសោធនកម្ម 2007 2015**

   *បង្កើតមូលដ្ឋានអង្គភាព និងបទប្បញ្ញត្តិ សម្រាប់សកម្មភាពដែលទាក់ទងនឹង **ការផ្គត់ផ្គង់អគ្គិសនី** និងរៀបចំក្របខណ្ឌ ដើម្បីគ្រប់គ្រងសកម្មភាពប្រសិទ្ធភាពថាមពល។*

2. **គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ – 2022-2030**

   *កំណត់**គោលដៅថ្នាក់ជាតិសម្រាប់កាត់បន្ថយ** ការប្រើប្រាស់ថាមពលសរុប 19% **នៅឆ្នាំ 2030** 34% **ក្នុងវិស័យលំនៅដ្ឋាន និង** 25% **ក្នុងវិស័យពាណិជ្ជកម្ម***

   *គោលនយោបាយនេះគាំទ្រគោលនយោបាយដទៃទៀត៖*

   ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាល IV ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នភាព ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា NDCs ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ផែនការយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍបៃតង និង គោលនយោបាយអភិវឌ្ឍឧស្សាហកម្ម។***




*ឯកសារយោង៖ 2022-2030, MME, Govt of Cambodia, National Energy Efficiency Policy*

# ប្រទេសកម្ពុជា

## គោលនយោបាយ សម្រាប់ប្រសិទ្ធភាពថាមពលអគារ និង សីតកម្ម

**ច្បាប់អគ្គិសនី**
ព្រះរាជក្រិត លេខ. NS/RKM/0201/03

2001, 2007, 2015

*កំណត់តួនាទីរបស់ភាគីសំខាន់ៗក្នុងវិស័យអគ្គិសនី MME & EAC និងការពារអ្នកប្រើប្រាស់ពីការកំណត់តម្លៃផ្តាច់មុខ*

2004, 2008, 2013,2018

*នយោបាយគោលសម្រាប់ ការអភិវឌ្ឍជាតិប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយពង្រឹងសមត្ថភាពបន្សាំ និងភាពធន់ នឹងការប្រែប្រួលអាកាសធាតុ និងការរួមចំណែកដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សរុប*

**យុទ្ធសាស្ត្រចតុកោណកម្ពុជាសម្រាប់កំណើនសមធម៌ការងារ និងប្រសិទ្ធភាព I,II,II,IV**

2009

**ផែនទីបង្ហាញផ្លូវ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង**

*លើកកម្ពស់ការអភិវឌ្ឍន៍ដែលមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវភាពធន់នឹងផលប៉ះពាល់អវិជ្ជមាន ខណៈពេលដែលជ្រើសរើសជម្រើសកាបូនទាប សម្រាប់" កំណើនបៃតង" ដើម្បីកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ*

2006,2009, 2019

*ផែនការនេះបង្ហាញពីគោលដៅអាទិភាព និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ក្នុងការកាត់បន្ថយភាពក្រីក្រឆាប់រហ័ស និងដើម្បីសម្រេច គោលគៅអភិវឌ្ឍន៍សហវត្សរ៍រមជ្ឈការ (CMDGs) ដទៃទៀតនិង គោលដៅ អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងគោលដៅអភិវឌ្ឍន៍សម្រាប់ប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងអស់។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) មានតួនាទីជាឧបករណ៍ដឹកនាំសម្រាប់យុទ្ធសាស្ត្រចតុកោណ ដើម្បីសម្រេចគោលដៅដែលបានចង់បាន។*

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) & បច្ចុប្បន្នភាព**

2013

**គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្តីពីប្រសិទ្ធភាពថាមពលនៅកម្ពុជា**

*ការពិនិត្យឡើងវិញអំពីគោលនយោបាយប្រសិទ្ធភាពថាមពលដែលបានអនុវត្តថ្មីៗជាមួយនឹងផែនការ និងគោលនយោបាយអភិវឌ្ឍន៍ប្រសិទ្ធភាពថាមពលក្នុងរយៈពេលខ្លី មធ្យម និងវែងនៅក្នុងវិស័យថាមពល។ គាំទ្រដល់ការអភិវឌ្ឍន៍គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ យុទ្ធសាស្ត្រប្រសិទ្ធភាពថាមពលជាតិ និងផែនការសកម្មភាពប្រសិទ្ធភាពថាមពលជាតិ។*

2014-2023

*ក្របខណ្ឌជាតិសម្រាប់ជំរុញការចូលរួមរបស់សាធារណជន វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ក្នុងដំណើរការប្រកបដោយការចូលរួម ក្នុងការឆ្លើយតបចំពោះបញ្ហាអាកាសធាតុ ដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព។*

**ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)**

*ប្រភព៖ UN ESCAP, https://asiapacificenergy.org/apef/index.html#main/lang/en/time/[2018,2024]/geo/[]/search*

# ប្រទេសកម្ពុជា

## គោលនយោបាយ សម្រាប់ប្រសិទ្ធភាពថាមពលអគារ និង សីតកម្ម

**ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (INDC)**

2016

*ឯកសារគោលនយោបាយពហុវិស័យក្នុង INDC កម្ពុជា បានស្នើរនូវការរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់រយៈពេល 2020-2030 ដែលផ្អែកលើលក្ខខណ្ឌនៃការគាំទ្រពីសហគមន៍អន្តរជាតិ។ វិស័យសំខាន់ៗរួមមាន ថាមពល កម្មន្តសាល និងការដឹកជញ្ជូន។*

2016 - 2018

*ផែនទីបង្ហាញផ្លូវសម្រាប់ភាគីពាក់ព័ន្ធនានា រួមទាំងអាជីវកម្ម ដើម្បីអនុវត្តសកម្មភាពដែលនឹងរួមចំណែកក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ និងឆ្ពោះទៅរកសេដ្ឋកិច្ចធន់នឹងកាបូនទាប។*

**ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់វិស័យរ៉ែ និងថាមពល**

**ផែនការថាមពលមូលដ្ឋានរបស់កម្ពុជា**

2019

*កំណត់គោលដៅជាតួលេខសម្រាប់បញ្ហាថាមពលនីមួយៗដែលគ្របដណ្តប់ដោយផែនការ គោលបំណងជាមូលដ្ឋាននៃផែនការគឺស្វែងរកការផ្គត់ផ្គង់ថាមពលសម្រាប់ប្រទេសកម្ពុជាជាមួយនឹងលក្ខខណ្ឌដូចខាងក្រោម៖ តម្លៃសមរម្យ លទ្ធភាពទទួលបានការប្រើប្រាស់ (accessability) សន្តិសុខថាមពល(សន្តិសុខប្រកបដោយនិរន្តរភាព) សុវត្ថិភាព និងតម្លាភាពនៅក្នុងទីផ្សារថាមពល។ វាគ្របដណ្តប់លើផ្នែកមូលដ្ឋានដូចជា ប្រេង ថាមពលកកើតឡើងវិញ **ប្រសិទ្ធភាពថាមពល** សន្តិសុខថាមពល និងទស្សនវិស័យថាមពល*

2020

*ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដោយដាក់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រហែល 42 ភាគរយពីសេណារីយ៉ូ BAU ត្រឹមឆ្នាំ 2030។ ក្នុងចំណោមគោលដៅនេះ វិស័យថាមពលបានក្លាយជាវិស័យធំទីពីរ ដែលមានតួនាទីសំខាន់ក្នុងការជួយសម្រេចគោលដៅ។*

**ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ**

**ច្បាប់សំណង់**

2019

*កំណត់គោលការណ៍ណែនាំសម្រាប់ក្របខណ្ឌច្បាប់នៃវិស័យសំណង់។ ច្បាប់នេះបានលើកឡើងអំពីប្រសិទ្ធភាពសំណង់ និងគោលគំនិតនៃអគារបៃតងដែលធានាការអភិវឌ្ឍន៍បៃតង ការការពារធនធានធម្មជាតិ និងបរិស្ថាន ការធានាគុណភាពសំណង់ សុវត្ថិភាព និងសន្តិសុខ និងការការពារលក្ខណៈសម្បត្តិ និងសុខុមាលភាពនៃសំណង់។ ការរួមបញ្ចូល បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមាក្នុងបទប្បញ្ញត្តិគឺជាភាពចាំបាច់ ដើម្បីជៀសវាងការជាប់នៅក្នុងបរិស្ថានដែលគ្មានប្រសិទ្ធភាព។*

*ប្រភព៖ UN ESCAP, https://asiapacificenergy.org/apef/index.html#main/lang/en/time/[2018,2024]/geo/[]/search*

# ប្រទេសកម្ពុជា

## គោលនយោបាយ សម្រាប់ប្រសិទ្ធភាពថាមពលអគារ និង ការផ្តល់ភាពត្រជាក់

**2020**

**ផែនការមេស្តីពីប្រសិទ្ធភាព និងការអភិរក្សថាមពលក្នុងប្រទេសកម្ពុជា**

*ផ្តោតសំខាន់លើ កម្មវិធី និងគោលនយោបាយ ៥ ចំណុចៈ 1) ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល, 2) បង្កើនចំនួនអ្នកគ្រប់គ្រងថាមពល, 3) ប្រព័ន្ធបទដ្ឋាន និងការបិទស្លាកសញ្ញា, 4) ការអប់រំ និងយុទ្ធនាការ, និង 5) ការរៀបចំសូចនាករប្រសិទ្ធភាពថាមពល។ វិស័យផ្តល់ភាពត្រជាក់(cooling sector )ត្រូវបានរួមបញ្ចូលក្នុងបទដ្ឋាននិងការបិទស្លាកសញ្ញា។*

**2020**

***បច្ចុប្បន្នភាពផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា***

*ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដោយដាក់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រហែល 42 ភាគរយពីសេណារីយ៉ូ BAU ត្រឹមឆ្នាំ 2030។ ក្នុងចំណោមគោលដៅនេះ វិស័យថាមពលបានក្លាយជាវិស័យធំទីពីរ ដែលមានតួនាទីសំខាន់ក្នុងការជួយសម្រេចគោលដៅ។*

**2021**

**សេចក្តីព្រាងផែនការយុទ្ធសាស្ត្រ NDC សម្រាប់អគារ និងសំណង់ដែលមានការបន្ថយកាបូន និងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដោយមានចក្ខុវិស័យដល់ឆ្នាំ 2050**

*ផែនការបង្ហាញផ្លូវត្រូវបានរៀបចំឡើងដើម្បី" គាំទ្រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) និងរាជរដ្ឋាភិបាលកម្ពុជា(RGC) ក្នុងការលើកកម្ពស់មហិច្ឆតាអាកាសធាតុក្នុងវិស័យនេះឲ្យកាន់តែស៊ីជម្រៅ ស្របតាមគោលដៅNDC របស់ប្រទេស ដែលបានធ្វើបច្ចុប្បន្នភាពដើម្បីបង្កើនគោលដៅការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងសេដ្ឋកិច្ចទាំងមូល( economy-wide mitigation targets ) និងការអនុវត្ត ត្រឹមឆ្នាំ2025 " ផ្តែកគាំទ្រទាំង ៨ គឺៈ "ផែនការទីក្រុង អគារថ្មី អគារមានស្រាប់ អគារ (ការកែលម្អឡើងវិញ) ប្រតិបត្តិការអគារ ប្រព័ន្ធ និងឧបករណ៍ សម្ភារៈ ភាពធន់ និងថាមពលស្អាត"*

**2022**

**គោលនយោបាយជាតិ ប្រសិទ្ធភាពថាមពលកម្ពុជា (NEEP)**

*រួមបញ្ចូលវិធានការដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលនៅកម្ពុជា ដោយបង្កើនប្រសិទ្ធភាពថាមពល។ វាកំណត់គោលដៅទូទាំងប្រទេស សម្រាប់ការកាត់បន្ថយការប្រើប្រាស់ថាមពល រួមជាមួយគោលដៅជាក់ស្តែងសម្រាប់វិស័យនីមួយៗ។*

**2023**

**អនុក្រឹត្យលេខ 254 ស្តីពីការគ្រប់គ្រង និងលើកម្ពស់ប្រសិទ្ធភាពថាមពលបរិក្ខារអគ្គិសនី**

*តម្រូវឱ្យឧបករណ៍អគ្គិសនីក្នុងប្រទេសកម្ពុជាមានស្លាកសញ្ញាប្រសិទ្ធភាពថាមពល និងត្រូវតាមស្តង់ដារជាក់លាក់*

**2023**

**ផែនការសកម្មភាពសីតកម្មជាតិ (NCAP)**

NCAP *បានកំណត់សកម្មភាពយ៉ាងទូលំទូលាយដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញឧស្ម័នចេញពីប្រព័ន្ធផ្តល់ភាពត្រជាក់ ស្របតាមផែនការដែលទាក់ទងនឹងការផ្លាស់ប្តូរសន្ទនីយ៍ធ្វើឲ្យត្រជាក់។ កម្ពុជា បានក្លាយជាប្រទេសដំបូងក្នុងការរៀបចំគម្រោងបង្ហាញដោយប្រើវិធីសាស្ត្រសមុព័ន្ធភាពផ្តល់ភាពត្រជាក់។*

*ប្រភពៈ UN ESCAP, https://asiapacificenergy.org/apef/index.html#main/lang/en/time/[2018,2024]/geo/[]/search*

# គោលនយោបាយជាតិ ប្រសិទ្ធភាពថាមពលកម្ពុជា (NEEP)

## គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ 2022 - 2030

### ទស្សនៈវិស័យ

'ដើមប្បីប្រែក្លាយការប្រើប្រាស់ថាមពលក្នុងប្រទេសកម្ពុជាដោយសម្របទៅតាមប្រសិទ្ធភាពថាមពល ដូច្នោះចូលរួមចំណែកសេដ្ឋកិច្ចប្រកួតប្រជែងរស់រវើក និងខ្លាំង ទន្ទឹមជំរុញការអភិវឌ្ឍន៍ប្រកបដោយចីរភាព។'

### ហេតុផល

អត្ថប្រយោជន៍ផ្សេងៗ ដែលសក្តានុពលភាពនៃប្រសិទ្ធភាពថាមពលផ្តល់ឲ្យដូចជា៖

1) ការធ្វើឲ្យប្រសើរនូវសន្តិសុខថាមពល
2) ការកាត់បន្ថយការចំណាយថាមពល និងការប្រកួតប្រជែងសេដ្ឋកិច្ចទាំងមូលខ្ពស់
3) ការកាត់បន្ថយការចំណាយលើថ្លៃរស់នៅ និង លុបបំបាត់ភាពក្រីក្រ
4) ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងសារធាតុបំពុលបរិស្ថានផ្សេងៗ
5) ការបង្កើតទីផ្សារថ្មីនៃបច្ចេកវិទ្យានិងសេវាកម្ម ប្រសិទ្ធភាពថាមពល

គោលនយោបាយផ្តោតលើ **ប្រសិទ្ធភាពថាមពលនៅផ្នែកតម្រូវការ** ដែលគ្របដណ្តប់លើកម្រិតនៃវិធានការដែលអាចត្រូវបានអនុវត្តនៅក្នុងវិស័យអ្នកប្រើប្រាស់ចុងក្រោយ ដើម្បីកាត់បន្ថយតម្រូវការថាមពលតាមរយៈការប្រើប្រាស់ថាមពលកាន់តែមានប្រសិទ្ធភាព។ គោលការណ៍នេះមិនគ្របដណ្តប់លើ ***ប្រសិទ្ធភាពថាមពលនៅផ្នែកផ្គត់ផ្គង់ ដែលអនុវត្តចំពោះការបង្កើត ការបញ្ជូន និងការចែកចាយថាមពល***នោះទេ។ ទិដ្ឋភាពទាំងនេះត្រូវបានគ្របដណ្តប់នៅក្នុង ***ផែនការមេអភិវឌ្ឍន៍ថាមពលរបស់កម្ពុជា (2022-2040)*** ។




*ប្រភព៖ NEEP, Royal Government of Cambodia 2022 - 2030.*

# រចនាសម្ព័ន្ធស្ថាប័ន

## គោលនយោបាយជាតិប្រសិទ្ធភាពថាមពល (NEEP)

1. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំដោយក្រសួងឧស្សាហកម្ម វិទ្យា សាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យនៅក្នុងឧស្សាហកម្ម

2 ២. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យនៅក្នុងអគារ

3 អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT)

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យក្នុងការងារសាធារណៈ និងដឹកជញ្ជូន

4. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំរដ្ឋបាលរាជធានី និងខេត្ត

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ ដោយរួមបញ្ចូលជាមួយស្ថាប័នរដ្ឋបាលរាជធានី និងខេត្ត

គណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




រចនាសម្ព័ន្ធអភិបាលកិច្ច NEEP

# វិស័យអគារ

## គោលដៅ NEEP & សសរស្តម្ភយុទ្ធសាស្ត្រ

### សសរស្តម្ភយុទ្ធសាស្ត្រក្នុងវិស័យអគារ & ផែនទីបង្ហាញផ្លូវការអនុវត្ត

| 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|
| កម្មវិធីស្តង់ដារនិងស្លាកសញ្ញា | ក្រមថាមពលសម្រាប់អគារ BEC | គោលការណ៍សម្រាប់អគារបៃតង GB | ការលើកទឹកចិត្ត | ការកសាងសមត្ថភាព |
| 2022-23 | 2023-24 | 2022-24 | 2022-24 | 2023 |

ផែនទីបង្ហាញផ្លូវការអនុវត្ត

### គោលដៅកាត់បន្ថយតាមវិស័យនីមួយៗ

- 34% លំនៅដ្ឋាន
- 25% ពាណិជ្ជកម្ម
- 20% ឧស្សាហកម្ម
- 29% សេវាសាធារណៈ
- 5% ការដឹកជញ្ជូន

គោលដៅការបន្ថយតាមវិស័យ

*ប្រភព ៖NEEP*

# វិស័យអគារ (ត)

## គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ (NEEP)

ប្រភេទអគារទាំង 8 ត្រូវបានកំណត់ជាអទិភាពសម្រាប់គិតពិចារណាក្នុងវិសាលភាពក្នុងគោលនយោបាយ៖ **អគារលំនៅដ្ឋាន អគារ ការិយាល័យ សណ្ឋាគារ អគារលក់ដុំនិងរាយ សាលារៀនមន្ទីរពេទ្យ ឃ្លាំង អគាររដ្ឋបាលសាធារណៈ**

**អគារលំនៅដ្ឋាន**

សក្តានុពលសម្រាប់ប្រសិទ្ធភាពថាមពលគឺត្រូវបានគិតពិចារណា ហើយត្រូវផ្តោតលើបរិក្ខារប្រើប្រាស់ក្នុងផ្ទះដែលមានប្រសិទ្ធភាពថាមពល ការកែលម្អការអនុវត្តការរចនាអគារ និងចង្ក្រានដែលសន្សំសំចៃថាមពល។

មានសារៈសំខាន់ក្នុងការផ្សព្វផ្សាយប្រើប្រាស់ទូរទឹកកក និងម៉ាស៊ីនត្រជាក់ប្រកបដោយប្រសិទ្ធភាពថាមពល និងការអនុវត្តន៍ការរចនាប្រកបដោយប្រសិទ្ធភាពថាមពល នឹងធ្វើឲ្យប្រសើរឡើងនូវផាសុកភាពកម្ដៅ ដើម្បីកាត់បន្ថយតម្រូវការថាមពលនៅក្នុងអគារលំនៅដ្ឋាន។



អគារលំនៅដ្ឋាន




ការិយាល័យ




សណ្ឋាគារ




អគារលក់ដុំនិងរាយ




សាលារៀន




មន្ទីរពេទ្យ




ឃ្លាំង



អគាររដ្ឋបាលសាធារណៈ

**ប្រភេទអគារ ត្រូវបានកំណត់ជាអទិភាពក្នុងវិសាលភាពក្នុងគោលនយោបាយ NEEP**

*ប្រភព ៖NEEP*

# វិស័យអគារ (ត)

## គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ (NEEP)

### អគារពាណិជ្ជកម្ម

ផ្ទៃក្រឡាដែលបានសាងសង់ឡើងនៃអគារពាណិជ្ជកម្មត្រូវបានគេប៉ាន់ស្មានថានឹងកើនឡើងពី 20 លានម៉ែត្រការ៉េក្នុងឆ្នាំ 2019 ដល់ 100 លានម៉ែត្រការ៉េនៅឆ្នាំ 2040 ។

ការប៉ាន់ប្រមាណនៃអាំងតង់ស៊ីតេនៃការប្រើប្រាស់ថាមពល (EUI) សម្រាប់ប្រភេទអគារផ្សេងៗគ្នា

ឱកាសប្រសិទ្ធភាពថាមពលនៅក្នុងផ្នែកបន្ទាប់បន្សំនេះគឺផ្តោតលើការប្រើប្រាស់ថាមពលសំខាន់ៗនៅក្នុងអគារពាណិជ្ជកម្ម ដែលពាក់ព័ន្ធនឹង ប៉ុន្តែមិនត្រូវបានកំណត់ចំពោះ សីតកម្មប្រកបដោយសុភភាព ភ្លើងបំភ្លឺ ប្រព័ន្ធផ្គត់ផ្គង់ទឹក ជណ្តើរយន្តយោង និងជណ្តើរយន្ត និងបន្ទុកផ្សេងទៀតអាស្រ័យលើប្រភេទអគារ។

| ប្រភេទអគារ | EUI (Annual kWh / square meters of built-up area) |
|---|---|
| ការិយាល័យ | 217 |
| អគារលក់ដុំនិងរាយ | 312 |
| សណ្ឋាគារ | 126 |
| មន្ទីរពេទ្យ | 153 |
| សាលារៀន | 84 |
| ឃ្លាំង | 115 |
| អគាររដ្ឋបាលសាធារណៈ | 217 |

ប្រភព ៖NEEP

# សកម្មភាពកាត់បន្ថយរបស់ NDC

## LTS4CN ការកាត់បន្ថយ, ការសម្របតាម និងសកម្មភាពដែលអាចអនុវត្តបាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងអព្យាក្រឹតកាបូន (LTS4CN) ជាផែនទីបង្ហាញផ្លូវ ឬឯកសារចក្ខុវិស័យដែលបង្ហាញពីសកម្មភាពកាត់បន្ថយជាអាទិភាពសម្រាប់វិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅរបស់ប្រទេសដែលមាបសេដ្ឋកិច្ចអព្យាក្រឹតកាបូននៅឆ្នាំ 2050 ។យុទ្ធសាស្ត្រភាគច្រើនបង្កើតលើការរួមចំណែករបស់ជាតិដែលបានធ្វើបច្ចុប្បន្នភាព។

### សកម្មភាពកាត់បន្ថយ

- មានចំនួន 33 បានកំណត់អាទិភាពក្នុង 7 វិស័យ
- មានចំនួន 7 សម្រាប់វិស័យសំណង់
- ការកាត់បន្ថយការបញ្ចេញឧស្ម័ន 42% ប្រៀបធៀបនឹងសេណារីយ៉ូធុរកិច្ចតាមទន្លាប់ធម្មតា (BAU)

### សកម្មភាព បន្សាំ៖

- 58 បានកំណត់អាទិភាពក្នុង 11 វិស័យ
- 6 សម្រាប់វិស័យសំណង់
- បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ




2021 -2023

| | |
|---|---|
| 7 | ការកាត់បន្ថយ |
| 6 | បន្សាំ |
| Nil | សកម្មភាពគាំទ្រ(ENABLING) |

**សកម្មភាពអនុវត្តនៅក្នុងវិស័យដែលមានឥទ្ធិពលលើឧស្សាហកម្មសំណង់ និងអគារ**

*ប្រភព ៖https://ncsd.moe.gov.kh/ndc-tracking/public/NDC/*

# ផែនការសកម្មភាពសីតកម្មជាតិ(NCAP)

## ការស្នើសុំអន្តរាគមន៍គោលនយោបាយរយៈពេលខ្លី (៥ឆ្នាំ) និងរយៈពេលមធ្យម (១០ឆ្នាំ)




### ការអន្តរាគមន៍គោលនយោបាយ៖

- បង្កើតក្រមអគារ និងការអនុវត្ត/ការចេញវិញ្ញាបនប័ត្រសម្រាប់អគារថ្មី និងអគារកែលម្អឡើងវិញ
- កាត់បន្ថយការពឹងផ្អែកលើម៉ាស៊ីនត្រជាក់នៅក្នុងអគារសាធារណៈ
- អនុម័តបទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា(MEPS) និងស្លាកសញ្ញាថាមពលសម្រាប់ម៉ាស៊ីនត្រជាក់




ប្រភព ៖NCAP

តម្រូវការភាពត្រជាក់សរុបតាមវិស័យក្នុងឆ្នាំ 2020, នឹងតាមសេណារីយ៉ូ BAU 2030 និង 2040




Source: Authors, NCAP Assessment

ការប្រើប្រាស់ថាមពលពីការផ្តល់ភាពត្រជាក់ក្នុងលំហអគារ តាមប្រភេទឧបករណ៍
ក្នុងឆ្នាំ 2020 និងក្នុងសេណារីយ៉ូពីរ ឆ្នាំ 2030 និង 2040

# ផែនការសកម្មភាពសីតកម្មជាតិ (NCAP)

## សកម្មភាពជាយុទ្ធសាស្ត្រទាក់ទងទៅនឹងសីតកម្មអគារ

### ការអន្តរាគមន៍បទប្បញ្ញត្តិ & ការអន្តរាគមន៍គោលនយោបាយ

SC1: បង្កើតក្រុមអគារ និងការអនុវត្ត/ការចេញវិញ្ញាបនប័ត្រសម្រាប់អគារថ្មី និងអគារកែលម្អឡើងវិញ

SC.2: កាត់បន្ថយការពឹងផ្អែកលើម៉ាស៊ីនត្រជាក់នៅក្នុងអគារសាធារណៈ

SC.3: បង្កើតប្រព័ន្ធមាត់ច្រកផលិតផល (product gateway system) ដើម្បីជួយការអនុវត្តការអនុលោមលើផលិតផលដែលមានច្បាប់

SC.4: អនុម័តបទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា (MEPS) និងការបិទស្លាកប្រសិទ្ធភាពថាមពលសម្រាប់ម៉ាស៊ីនត្រជាក់

SC.5: អនុលោមតាមស្តង់ដារការគុណផលប៉ះពាល់អាកាសធាតុទាប (low-climate impact performance standards )សម្រាប់ទ្រព្យសកម្មរបស់ទីក្រុងថ្មីទាំងអស់ (ឬក្នុងអំឡុងពេលតំហែទាំជាទៀងទាត់ និងវដ្តនៃការកែលម្អឡើងវិញ)។

### ការអន្តរាគមន៍បច្ចេកវិទ្យា

SC6:រួមបញ្ចូលតម្រូវការគុណផលសម្រាប់ប្រព័ន្ធត្រជាក់អកម្មនៅក្នុងក្រមថាមពលអគារ

SC.2:ផ្សព្វផ្សាយ និងលើកទឹកចិត្តដល់ការប្រើប្រាស់ម៉ាស៊ីនត្រជាក់ដែលមានប្រសិទ្ធភាពថាមពល ដោយផ្អែកលើកម្រិតខ្ពស់បំផុតដែលបានកំណត់ក្នុងស្លាកសញ្ញាថាមពល

SC.3: បង្កើនការប្រើប្រាស់ប្រព័ន្ធឆិល័រប្រភេទប្រើកម្លាំងចាកផ្ចិតប្រកបដោយប្រសិទ្ធភាពថាមពល

SC.4: លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធលំហូរសីតករប្រែប្រួល (VRV) ដែលមានប្រសិទ្ធភាពថាមពល

SC.5: លើកកម្ពស់ប្រសិទ្ធភាពថាមពលក្នុងកង្ហារ

# សេចក្តីថ្លែងអំណរគុណ

កម្មវិធីបណ្តុះបណ្តាលអគារកាបូនទាប (LCB) ដឹកនាំដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) សម្រាប់រយៈពេល 2024-2027

## ដឹកនាំកម្មវិធីបណ្តុះបណ្តាលអគារកាបូនទាបដោយៈ

លោកស្រីបណ្ឌិត វង់ច័ន្ទ គីនណាលេត (អ្នកដឹកនាំ)

- អ៊ីម៉េលៈ kinnalethv@yahoo.co.uk
- ទូរស័ព្ទលេខៈ (+855) 99 351 199

លោកបណ្ឌិត ចាន់ សារិន្ទ (ទីប្រឹក្សា)

- អ៊ីម៉េលៈ sarinchan@itc.edu.kh
- ទូរស័ព្ទលេខៈ (+855) 99 351 199

លោកបណ្ឌិត ហ៊ាង ឡាទីន (អ្នកបច្ចេកទេស និងជំនួយការអ្នកគ្រប់គ្រង)

លោក ជា ចន្ទតុលា (អ្នកបច្ចេកទេស និងអ្នករៀបចំព្រឹត្តិការណ៍)

## អ្នកកែសម្រួល និងសម្របសម្រួលការបកប្រែៈ

លោកស្រីបណ្ឌិត វង់ច័ន្ទ គីនណាលេត

លោកបណ្ឌិត ហ៊ាង ឡាទីន

លោក វិធាន ខេមរដ្ឋ

លោក ជា ចន្ទតុលា

## សមាជិកអ្នកបកប្រែៈ

លោកបណ្ឌិត សាន វិបុល លោកបណ្ឌិត ជូ ផានិត

លោកបណ្ឌិត សេង ស៊ុនហ៊ រ លោកបណ្ឌិត អ៊ិត អ៊ូដាយ៉ាលោក លី សូហេង លោក នុន សុផាន់ណា

កញ្ញា ហូ សូតាស៊ីង កញ្ញា ស្រ៊ុន ស្រីណា

លោក វិញ ឡាយអ៊ួ លោក លី លាងហុង

## អ្នកត្រួតពិនិត្យៈ

លោកបណ្ឌិត ចាន់ សារិន្ទ លោកបណ្ឌិត សាន វិបុល

លោកបណ្ឌិត សេង ស៊ុនហ៊ រ លោកបណ្ឌិត អ៊ិត អ៊ូដាយ៉ាលោកបណ្ឌិត រៃ សុភ័ក្រ លោក លី សូហេង

លោក នុន សុផាន់ណា លោក ហាស់ ចាន់លី

លោក វិធាន ខេមរដ្ឋ លោកបណ្ឌិត ហ៊ាង ឡាទីន

# សូមអរគុណ

**សំគាល់៖** ឯកសារនេះត្រូវបានបកប្រែពីឯកសារដើមជាភាសាអង់គ្លេស និងកែសម្រួលតាមបរិបទបច្ចេកទេសថាមពល និងកាបូនទាបក្នុងវិស័យសំណង់អគារ។ ក្នុងករណីដែលលោកអ្នករកឃើញមានកំហុសឆ្គង ឬចង់ផ្តល់ជាមិតក្នុងការកែសម្រួល សូមផ្តល់ព័តមានមកកាន់គម្រោង ALCBT តាមរយៈអ៊ីម៉ែល៖ chan.suong@gggi.org ឬ heang.latin@itc.edu.kh

**យន្តការបណ្តឹងឯករាជ្យរបស់ ការផ្តួចផ្តើមអាកាសធាតុសកល (IKI)**

បុគ្គលណាដែលជឿថាពួកគេអាចរងផលប៉ះពាល់ដោយគម្រោង IKI ឬដែលចង់រាយការណ៍អំពីអំពើពុករលួយ ឬការប្រើប្រាស់មូលនិធិមិនត្រឹមត្រូវ អាចដាក់ពាក្យបណ្តឹងទៅកាន់យន្តការបណ្តឹងឯករាជ្យរបស់ IKI តាមរយៈ IKI-complaints@z-u-g.org ។ យន្តការបណ្តឹងរបស់ IKI មានក្រុមអ្នកជំនាញឯករាជ្យដែលនឹងធ្វើការស៊ើបអង្កេតលើបណ្តឹងនោះ។ នៅក្នុងដំណើរការនៃការស៊ើបអង្កេត យើងនឹងពិគ្រោះយោបល់ជាមួយដើមបណ្តឹង ដើម្បីជៀសវាងហានិភ័យដែលមិនចាំបាច់សម្រាប់ដើមបណ្តឹង។ ព័ត៌មានបន្ថែមអាចរកបាននៅ https://www.international-climate-initiative.com/en/about-iki/values-responsibility/independent-complaint-mechanism/ ។

ព័ត៌មានទំនាក់ទំនង/អាសយដ្ឋាន

alcbt.gggi.org
@gggi_hq
@GGGIHQ

@GGGIHQ
@gggi_hq
@GGGIMedia

Supported by:

Federal Ministry for the Environment, Climate Action, Nature Conservation and Nuclear Safety

based on a decision of the German Bundestag